# របាយការណ៍

## ឯកឧត្តមបណ្ឌិត ជាម យៀប

## ប្រធានគណៈកម្មការ រៀបចំជួសជុល និងសាងសង់វិមានរដ្ឋសភាថ្មី

## ថ្លែងក្នុងពិធីសម្ពោធវិមានរដ្ឋសភា នាថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៧

- សូមក្រាបថ្វាយបង្គំ សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** គណៈមហានិកាយ
- បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
- សូមក្រាបថ្វាយបង្គំ ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត
- ឯកឧត្តមប្រធានសភា ឯកឧត្តមតំណាងសភានៃបណ្ដាប្រទេស ជាមិត្តទាំងអស់ជាទីគោរព
- ឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត និង តំណាងស្ថានទូត ទាំងអស់ជាទីគោរពរាប់អាន
- សូមគោរព សម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា
- សូមគោរព សម្ដេច **ហេង សំរិន** ប្រធានរដ្ឋសភា
- សូមគោរព ឯកឧត្តម **ងួន ញ៉ិល** អនុប្រធានទី ១ នៃរដ្ឋសភា
- សូមគោរព ឯកឧត្តម **ហុង ស៊ុនហួត** អនុប្រធានទី ២ នៃរដ្ឋសភា
- សូមគោរព សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល កម្ពុជា
- ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងអង្គពិធីទាំងមូលជាទីគោរពស្នេហា

ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្ស បវរមហាប្រសើរដែលរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី ៣ បានប្រារព្ធពិធីសម្ពោធបញ្ចប់ការស្ថាបនាវិមានរដ្ឋសភា បន្ទាប់ពីគណៈកម្មការសាងសង់បានទទួលសំណង់ពីក្រុមហ៊ុនសាងសង់ និងសូមប្រគល់វិមានរដ្ឋសភានេះជូនទៅសម្ដេចប្រធានរដ្ឋសភា ដើម្បីសម្ដេចចាត់ចែងទៅតាមតម្រូវការងាររបស់រដ្ឋសភាតទៅ ។ ពិធីសម្ពោធ នាថ្ងៃនេះ គឺថ្ងៃ សៅរ៍ ទី ០៧ ខែ កក្កដា

គឺខែទី ០៧ ឆ្នាំ ២០០៧ ( ០៧ . ០៧ . ០៧ ) ក៏ជាឆ្នាំទី ៦០ នៃការកកើតនូវរដ្ឋសភានៃប្រទេសកម្ពុជា (១៩៤៧–២០០៧) ដែលយើងអាចចាត់ទុកថាជាថ្ងៃប្រវត្តិសាស្ត្រ និងជាព្រឹត្តិការណ៍ដ៏សំខាន់ចំពោះប្រជារាស្ត្រខ្មែរទូទៅផងដែរ ។ តាងនាមគណៈកម្មការសាងសង់វិមានរដ្ឋសភា និងក្នុងនាមទូលព្រះបង្គំខ្ញុំផ្ទាល់ ទូលព្រះបង្គំខ្ញុំសូមសម្តែងនូវការដឹងព្រះករុណាទិគុណ និងអរព្រះគុណចំពោះព្រះករុណាជាអម្ចាស់ ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេចប្រធានព្រឹទ្ធសភា សម្តេចប្រធានរដ្ឋសភា សម្តេចនាយករដ្ឋមន្ត្រី សម្តេច ម្ចាស់ក្សត្រីយ៍ អ្នកអង្គម្ចាស់ អ្នកអង្គម្ចាស់ក្សត្រីយ៍ លោកជំទាវ ឯកឧត្តម ជាគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ពិសេសឯកឧត្តមប្រធានរដ្ឋសភានៃប្រទេសជាមិត្ត និងអង្គទូតនានាដែលបានទ្រង់យាង និងអញ្ជើញមកចូលរួមជាព្រះរាជអធិបតីដ៏ខ្ពង់ខ្ពស់ និងជាអធិបតីក្នុងពិធីសម្ពោធវិមានរដ្ឋសភាប្រកបដោយភាពអធិកអធមក្រៃលែងនាពេលនេះ។

- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី បពិត្រព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីសក្ការៈ
- សម្តេច ម្ចាស់ក្សត្រីយ៍ អ្នកអង្គម្ចាស់ អ្នកអង្គម្ចាស់ក្សត្រីយ៍ ឯកឧត្តម លោកជំទាវ គណៈអធិបតី ភ្ញៀវកិត្តយសជាតិ អន្តរជាតិជាទីគោរព

ដើម្បីទ្រង់ព្រះសណ្តាប់ តទៅទូលព្រះបង្គំខ្ញុំសូមទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រមទាំងអង្គពិធីទាំងមូលទ្រង់ជ្រាប និងជ្រាបនូវគោលបំណង និងសកម្មភាពនៃការសាសង់វិមានរដ្ឋសភានេះ ។ ទូលព្រះបង្គំ ខ្ញុំសូមព្រះរាជានុញ្ញាត និងអនុញ្ញាតធ្វើរបាយការណ៍ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ :

រដ្ឋសភាជាអង្គការនីតិប្បញ្ញត្តិ ដែលមានចែងក្នុងជំពូកទី ៧ ចាប់ពីមាត្រា ៧៦ ដល់មាត្រា ៩៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ។ នៅកម្ពុជារដ្ឋសភាបានកើតឡើងតាំងពីមុនពេលដែលព្រះករុណា ព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រនៃព្រះរាជា

ណាចក្រកម្ពុជា ទ្រង់បានទាមទារពីបារាំងនូវឯករាជ្យ បូរណភាព ទឹកដីជូនប្រជារាស្ត្រខ្មែរ និងប្រទេសជាតិមកម្ល៉េះ ។ ព្រះអង្គទ្រង់បានដឹកនាំការរៀបចំតាក់តែងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាជាលើកដំបូងនៅឆ្នាំ ១៩៤៧ នៃរដ្ឋសភា លើកទី ១ នៅពេលមុនព្រះរាជាណាចក្រកម្ពុជាបានទទួលឯករាជ្យពេញបរិបូរណ៍នា ឆ្នាំ ១៩៥៣ ។

នៅចុងទសវត្សរ៍ឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៩០ ក្រោយពីមានសង្គ្រាមរ៉ាំរ៉ៃជាងពីរទសវត្សរ៍កន្លងមក ក្រោមព្រះអគ្គមគ្គុទេសកដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះករុណាព្រះមហាវីរក្សត្រ នៅថ្ងៃ ២៣ ខែ តុលា ឆ្នាំ ១៩៩១ កិច្ចព្រមព្រៀងនាទីក្រុងប៉ារីសត្រូវបានចុះហត្ថលេខាបញ្ចប់សង្គ្រាមជាស្ថាពរ ។ គ្រប់ភាគីនយោបាយខ្មែរទាំងអស់បានស្រុះស្រួលគ្នាជាឯកច្ឆន្ទថ្វាយព្រះករុណា ព្រះមហាវីរក្សត្រជាព្រះប្រធាននៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសខាងលើស្តីពីដំណោះស្រាយនយោបាយនៅកម្ពុជា ព្រមទាំងផ្តល់តួនាទីដឹកនាំយ៉ាងទូលំទូលាយជូនចំពោះអង្គការសហប្រជាជាតិនៅកម្ពុជា ហៅថា " អ៊ុនតាក់ " ទៀតផង ។ មហាត្រកូលខ្មែរដែលបែកបាក់គ្នាបានមករួបរួមគ្នាឡើងវិញហើយនៅខែ ឧសភា ឆ្នាំ ១៩៩៣ ប្រជារាស្ត្រខ្មែរទូទាំងប្រទេស បាននាំគ្នាបោះឆ្នោតជាសកល ជ្រើសរើសតំណាងរាស្ត្ររបស់ខ្លួនដោយស្របច្បាប់ មានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

សភាធម្មនុញ្ញមួយត្រូវបានប្រារព្ធបើកនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៣ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះករុណាព្រះបាទ សម្តេច **ព្រះនរោត្តម សីហនុ** ព្រះប្រមុខរដ្ឋនៃកម្ពុជា ដែលជាព្រះបិតាស្ថាបនាជាតិ ព្រះបិតាផ្សះផ្សាជាតិ ព្រះបិតាបង្រួបបង្រួមជាតិ និងជាព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដោយមានការចូលរួមពីឯកឧត្តម **យ៉ាស៊ូស៊ី អាកាស៊ី** ប្រមុខអ៊ុនតាក់ ជាតំណាងឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ។ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៣ សភាធម្មនុញ្ញបានដំណើរការងាររបស់ខ្លួន ដោយមានសមាជិក សមាជិកា ជាតំណាងរាស្ត្រ ចំនួន ១២០ រូប ហើយបានជ្រើសរើសប្រធានសភាធម្មនុញ្ញ និងអនុប្រធាន ២ រូប ដែលមាន

សម្តេចបវរសេដ្ឋា **សឺន សាន** ជាប្រធានសភាធម្មនុញ្ញ អមដោយអនុប្រធាន ២ រូប គឺ សម្តេច **ជា ស៊ីម** ជាអនុប្រធានទី ១ និងឯកឧត្តម **អ៊ឹង គៀត** ជា អនុប្រធានទី ២ ។ យោងជំពូកទី ១៦ មាត្រា ១៥៥ នៃរដ្ឋធម្មនុញ្ញ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ នៅក្នុងនីតិកាលទី ១ បន្ទាប់ពីបានធ្វើការអនុម័តច្បាប់រដ្ឋធម្មនុញ្ញរួចមក សភាធម្មនុញ្ញ បានក្លាយជារដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជារបស់ខ្លួនដោយរដ្ឋសភាបានអនុម័តជ្រើស តាំងសម្តេច **ជា ស៊ីម** ជាប្រធានរដ្ឋសភា ឯកឧត្តម **ឡូយ ស៊ីមឈាង** ជាអនុប្រធានទី ១ និងឯកឧត្តម **សឺន ស៊ូប៊ែរ្តិ៍** ជាអនុប្រធានទី ២ ។

នៅចុងនីតិកាលទី ១ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពី គណបក្សនយោបាយ នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ និងនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រជាសកលលើកទី ២ ដោយខ្លួនឯងនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ។ រដ្ឋសភានីតិកាលទី ២ មានសមាជិក សមាជិកា ១២២ រូប ដែលបានជាប់ឆ្នោត ក្រោមការដឹកនាំនៃសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ជាព្រះប្រធាន សម្តេច **ហេង សំរិន** ជាអនុប្រធានទី ១ និងឯកឧត្តម **ចែម ស្គួន** ជាអនុប្រធានទី ២ នៃរដ្ឋសភា ។ ក្រោយពី មរណភាពនៃឯកឧត្តម **ចែម ស្គួន** ដោយរោគាពាធ រដ្ឋសភាបានបោះឆ្នោតជ្រើសតាំង ឯកឧត្តម **ងួន ញ៉ិល** ជាអនុប្រធានទី ២ ជំនួសវិញ ។

- បពិត្រសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ព្រះថេរានុត្ថេរៈគ្រប់ ព្រះអង្គជាទីសក្ការៈ
- បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីសក្ការៈ
- គណៈអធិបតី ជាទីគោរពដ៏ខ្ពង់ខ្ពស់

ដោយយល់ថា ទីតាំងរដ្ឋសភាដែលមានអគារចាស់ទ្រុឌទ្រោមណាស់ទៅហើយ ដែលបានសង់តាំងពីឆ្នាំ ១៩១៧ បានបើកឱ្យប្រើប្រាស់ នៅឆ្នាំ ១៩២០ ត្រូវបានធ្វើការ ជួសជុល ៥ ដងរួចមកហើយ ។ មន្ទីររដ្ឋសភានេះមានទីតាំងតូចចង្អៀតដែលមានទំហំតែ

៤៤.៥៣ អារ ប៉ុណ្ណោះ ហើយមិនអាចធានាការបំពេញករណីយកិច្ច ជាប្រវត្តិសាស្ត្រជូនតំណាងរាស្ត្រគ្រប់រូប និងមន្ត្រីរាជការក្នុងអគ្គលេខាធិការដ្ឋានជាងមួយពាន់នាក់ដែលកំពុងបំរើការងារជូនរដ្ឋបាន ទើបនៅក្នុងនីតិកាលទី ២ នៃរដ្ឋសភា សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** អតីតព្រះប្រធានរដ្ឋសភា សម្តេច **ហេង សំរិន** ឯកឧត្តម **ង្វួន ញ៉ិល** ជាអនុប្រធានទាំង ២ នៃរដ្ឋសភា ទ្រង់បានយកព្រះទ័យផ្តួចផ្តើមព្រះតម្រិះ និងយកចិត្តទុកដាក់ធ្វើគម្រោងសាងសង់វិមានរដ្ឋសភា និងដើម្បីរៀបចំស្ថាប័ននីតិប្បញ្ញត្តិដែលជាស្ថាប័នកំពូលរបស់ជាតិឱ្យស័ក្តិសមបំពេញបាននូវសំណូមពរ និងតម្រូវការចាំបាច់របស់តំណាងរាស្ត្រក្នុងការបំពេញភារកិច្ចចំបងសម្រាប់បំរើម្ចាស់ឆ្នោត និងប្រទេសជាតិ ។ វិមានជាប្រវត្តិសាស្ត្រនេះ គឺជាកន្លែងធ្វើការនៃស្ថាប័នកំពូលរបស់រដ្ឋដែលមានរចនាប័ទ្មខ្មែរសម័យលង្វែក–ឧត្តុង្គ ដោយបង្កប់នូវវប្បធម៌ អរិយធម៌ និងនយោបាយជាតិខ្មែរដែលយើងកំពុងប្រារព្ធពិធីសម្ពោធវិមានដ៏ធំ និងថ្មីសន្លាងនាពេលនេះ ។

រដ្ឋសភាក្នុងនីតិកាលទី ៣ ដែលដឹកនាំដោយសម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា ឯកឧត្តមអនុប្រធានទី ១ និងឯកឧត្តម អនុប្រធានទី ២ សូមសម្តែងនូវការដឹងគុណ និងអរគុណចំពោះ សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាចំពោះរដ្ឋសភា និងឯកភាពយល់ព្រមផ្តល់ទីកន្លែងសាងសង់ និងថវិការដ្ឋសម្រាប់សាងសង់វិមានរដ្ឋសភាកន្លងមក ។

តទៅនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំបាទសូមព្រះរាជានុញ្ញាត និងអនុញ្ញាតរាយការណ៍ទូលថ្វាយ និងជំរាបជូនអំពីប្រវត្តិស្នើសុំទីតាំងសាងសង់វិមានរដ្ឋសភាពីសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលមានដំណាក់កាលដូចតទៅនេះ :

**លើកទី ១ :** មុនការបោះឆ្នោតឆ្នាំ ១៩៩៣ រដ្ឋសភានៃរដ្ឋកម្ពុជា ដែលមានសម្តេច **ជា ស៊ីម** ជាប្រធាន បានត្រូវរដ្ឋាភិបាលផ្តល់ទីតាំងស្ថិតនៅខាងកើតវិមានរដ្ឋ

ចំការមនឱ្យសាងសង់វិមានរដ្ឋសភាថ្មី ។ តែដោយមានសំណង់អនាធិបតេយ្យច្រើនពេក ដោះស្រាយមិនចេញក៏អាក់ខានទៅ ។

**លើកទី ២ :** នៅដើមនីតិកាលទី ២ រដ្ឋសភាដឹកនាំដោយសម្តេចក្រុមព្រះ ព្រះប្រធានរដ្ឋសភាបានស្នើសុំទៅរាជរដ្ឋាភិបាល នូវអគារវិមានរាជរដ្ឋាភិបាលដែលជាទីតាំងរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC ) តែដោយមានមន្ត្រីរាជការច្រើនរយនាក់ស្នាក់នៅតាំងពីជំនាន់ អ៊ុន តាក់ ក៏មិនអាចដោះស្រាយបានដែរ ។

**លើកទី ៣ :** រដ្ឋសភាបានស្នើសុំម្តងទៀតនូវសាលមហោស្រពព្រះសុរាម្រិត " **ទន្លេបាសាក់** " និងទីតាំងពិព័រណ៍អចិន្ត្រៃយ៍ ។ សម្តេចនាយករដ្ឋមន្ត្រីក៏សុខចិត្តយល់ព្រមឱ្យទៀត តែដោយមានការស្នើសុំពីសម្តេចព្រះរាម **បុប្ផា ទេវី** អតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈក៏អាក់ខានតទៅទៀត ។

**នៅលើកទី ៤ :** ដោយបានដំណឹងថាទីតាំងបច្ចុប្បន្នស្ថិតនៅទំនេរនោះ រដ្ឋសភាក៏ធ្វើលិខិតស្នើសុំម្តងទៀត ។ សម្តេចនាយករដ្ឋមន្ត្រីក៏ប្រគល់ឱ្យមករដ្ឋសភាជាថ្មីម្តងទៀត គឺទីតាំងវិមានរដ្ឋសភានេះ ដែលបានរៀបចំធ្វើប្លង់ និងប័ណ្ណកម្មសិទ្ធិរបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាស្របតាមផ្លូវច្បាប់ ។

សូមទ្រង់ព្រះមេត្តាប្រោស ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ជាទីគោរពស្នេហា

ទូលព្រះបង្គំខ្ញុំ ព្រះករុណាខ្ញុំសូមព្រះរាជានុញ្ញាត និងអនុញ្ញាតទូលថ្វាយ និងជំរាបជូនអង្គពិធីតទៅទៀតនូវខ្លឹមសារសង្ខេបនៃគម្រោងប្លង់សម្រាប់សាងសងវិមាននៃរដ្ឋសភាដូចខាងក្រោម :

យោងតាមការណែនាំរបស់សម្តេចក្រុមព្រះ **នរោត្តម រណប្ញទ្ធិ** ដែលពេលនោះជាព្រះប្រធាន និងថ្នាក់ដឹកនាំទាំងអស់នៃរដ្ឋសភា វិមានថ្មីនៃរដ្ឋសភាត្រូវតែសាងសង់ឱ្យស្របតាមរចនាប័ទ្មខ្មែរសម័យ លង្វែក – ឧត្តុង្គ មើលពីក្រៅ និងមានការបំពាក់សម្ភារៈ

បរិក្ខារ ព្រមទាំងសេវានានាសម្រាប់ប្រើប្រាស់ខាងក្នុងអគារស្របតាមស្តង់ដារអន្តរជាតិ តែមិនឱ្យខ្ពស់លើសពីលទ្ធភាពឡើយ ។

## ១. រូបភាពខាងក្រៅ :

គម្រោងសំណង់វិមានរដ្ឋសភានេះមាន " កំពូលបី " តុបតែងលម្អតាមលំនាំរចនាប័ទ្ម កំពូលប្រាសាទបុរាណខ្មែរសុទ្ធសាធ ដោយមានក្បាច់តុបតែងលម្អ និងទម្រង់ជាត្រីសូល៍បីឆ្ពោះទៅលើអាកាសវេហាស៍យ៉ាងខ្ពស់ត្រដែតដែលមានកំពស់ខ្ពស់ជាងគេគឺ ៧៩ ម៉ែត្រ និងព័ទ្ធជុំវិញដោយគូទឹក (ឬកសិណ) ដែលជានិមិត្តរូប "ភ្នំមេរុ" នៅចំកណ្តាលនៃមហាសាគរ និងមានតួអគារ ៤ នៅតាមជ្រុង គឺជានិមិត្តរូបនៃឧបទ្វីបទាំង ៤ ។ កសិណទឹកដែលនៅព័ទ្ធជុំវិញនៃសំណង់នេះ សិក្សាឡើងដោយអ្នកបច្ចេកទេស ដែលមានសមត្ថភាពអន្តរជាតិ ទីនោះជាអាងសម្រាប់ផ្ទុកទឹកភ្លៀងកុំឱ្យហូរចាក់ទៅលើសួនច្បារ ផ្លូវ និងចំណតរថយន្ត ហើយជាប្រយោជន៍ ដើម្បីប្រើប្រាស់សម្រាប់ស្រោចស្រពសួនច្បារនៅរដូវប្រាំង និងជួយឱ្យមានចំហាយត្រជាក់ដល់អគារផង ហើយអាចចាត់ទុកជាអាងដ៏សំខាន់មួយទៀតសម្រាប់យកទឹកពន្លត់ភ្លើងនៅពេលមានអគ្គិភ័យកើតឡើង ។ បើពិនិត្យមើលចំពីមុខនៃវិមាននេះឃើញមាន " កំពូលត្រីសូល៍ស្រួចបី " ដូចជាការមើលឃើញកំពូលបីនៃ "ប្រាសាទអង្គរវត្ត" បើគេមើលចំពីមុខ ឬពីក្រោយ ។

កំពូលទាំងបីនេះ ជានិមិត្តរូបនៃបាវចនា " ជាតិ សាសនា ព្រះមហាក្សត្រ " ជាបាវចនាគ្រឹះរបស់សង្គមរុងរឿងមួយនាសម័យសង្គមរាស្ត្រនិយមជឿនលឿន ក្រោមព្រះរាជកិច្ចដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា ព្រះបាទ **នរោត្តម សីហនុ** ជាព្រះវររាជបិតាឯករាជ្យជាតិ ព្រះបិតាផ្សះផ្សា បង្រួបបង្រួមជាតិ និងព្រះបិតាស្ថាបនាជាតិ ។ នៅកំពូលធំចំកណ្តាល ផ្នែកខាងចុងមានរំលេចដោយចម្លាក់រូបព្រះព្រហ្មញញឹម " មុខបួន " ដែលជាតំណាងនៃព្រហ្មវិហារធម៌ទាំងបួន ។

ព្រហ្មវិហារធម៌ប្រែថាគោលនៃការប្រព្រឹត្តិដែលប្រសើរ បរិសុទ្ធ " ធម៌ជាទីអាស្រ័យរបស់ព្រះព្រហ្ម " ពោលគឺព្រះព្រហ្មមានធម៌ទាំង ៤ នេះ ប្រចាំព្រះហឫទ័យរបស់ព្រះអង្គជាធម៌ដ៏ប្រពៃសម្រាប់អគ្គមគ្គុទេសក៍ប្រព្រឹត្តិចំពោះប្រជានុរាស្ត្រទូទៅ និងជាសីលធម៌សម្រាប់មាតាបិតាប្រព្រឹត្តិចំពោះបុត្រធីតា ។ ព្រហ្មវិហារធម៌មាន ៤ យ៉ាងគឺ :

១. មេត្តា : ការមានចិត្តអាណិតស្រឡាញ់ចង់ឱ្យអ្នកដទៃបានសុខ ។

២.ករុណា : ការមានចិត្តសន្ដោសជួយសង្គ្រោះឱ្យអ្នកដទៃប្រាស់ចាករួចពីទុក្ខ ។

៣. មុទិតា : ការមានចិត្តត្រេកអរពេលដែលអ្នកដទៃបានសុខ ឬមានកិត្តិយស ។

៤. ឧបេក្ខា : ការមានចិត្តដាក់កណ្ដាល ប្រាសចាកការភ័យខ្លាចមិនលម្អៀងដោយការស្រឡាញ់ ច្រណែន ឬស្អប់ខ្ពើម ។

ម្យ៉ាងទៀត កំពូលទាំងបីនេះជានិមិត្តរូបនៃស្ថាប័នកំពូលរបស់ជាតិ កំណត់ដោយរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ជំពូកទី ៤ មាត្រា ៥១ បានបែងចែកអំណាចជា ៣ គឺ :

- នីតិប្បញ្ញត្តិ
- នីតិប្រតិបត្តិ
- តុលាការ

នៅជំពូកទី ៣ មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាបានចែងថា : " ព្រះពុទ្ធសាសនា ជាសាសនា របស់រដ្ឋ " ។ ដូចនេះកំពូលទាំង ៣ នេះក៏អាចជានិមិត្តរូបនៃត្រៃសរណគមន៍ផងដែរគឺ :

- ព្រះពុទ្ធ
- ព្រះធម៌
- ព្រះសង្ឃ

ជាពិសេសប្លង់វិមាននេះគឺជាការបញ្ជាក់ពីគោលជំហរ នៃការគោរពចំពោះប្រពៃណីដ៏យូរលង់មកហើយនៃសង្គមកម្ពុជា ដែលគេតែងតែគោរព មេ–បា ឬ ទឹក–ដី ។ ដូច្នេះហើយ បើយើងពិនិត្យមើលលក្ខណៈប្លង់ពីផ្លូវចូលច្រកធំខាងមុខរហូតដល់ក្រោយប្រៀបបានទៅនឹងមហិទ្ធិរិទ្ធិនៃសត្វ " នាគ " ។ ការពន្លេចឡើងនូវឧរុង្គសត្វ សត្វនាគនៅក្នុងទស្សនៈខ្មែរបុរាណគេចាត់ទុកសត្វនាគជាតំណាងនៃទឹកដី និងភាពត្រជាក់ត្រជុំ ព្រោះថាសត្វនាគជាពពួកសត្វដែលរស់នៅលើគោកផង និងក្នុងទឹកផង ហើយមានមហិទ្ធិរិទ្ធិខ្លាំងក្លាដោយសត្វនេះជាពពួកសត្វមានសំណាកអាចមានអាយុវែង ។ ទាំងនេះ បង្ហាញឱ្យឃើញពីភាពស្ថិតស្ថេររបស់សង្គមតទៅអនាគតដ៏រុងរឿង ។

នៅច្រកចូលពីមុខនៃក្លោងទ្វារមានរូបសំណាក "ឆ្មាំ ២ នាក់ ឈរកាន់ដំបង" រាងមាំ សង្ហារ និងអង់អាចខ្លាំងក្លាការពារ និងរក្សានូវសុវត្ថិភាពដល់ថ្នាក់ដឹកនាំ និងសមាជិកសភាទាំងអស់ ។ តួនៃវិមានស្ថិតនៅលើព្រលានខ្ពស់ផុតពីដី ព្រមទាំងមានកាំជណ្ដើរធំៗឡើងចំពីមុខ នៅសងខាងកាំជណ្ដើរមានដាក់តំកល់ "រូបតោ" ដែលជាតំណាងនៃស្ដេចម្រឹគីម្រឹគាដែលជាឆ្មាំដ៏មានអំណាចក្នុងការការពារ និងថែរក្សាយ៉ាងមុតមាំចំពោះច្បាប់រដ្ឋធម្មនុញ្ញ ។ រូបតោនេះតុបតែងលម្អលំនាំរូបតោនៃរចនាប័ទ្មអង្គរវត្ត ។ ជាប់នឹងច្រកចូលធំនៃវិមានមានរូប " ទេពប្រណម្យ " អមសងខាងមាត់ទ្វារដែលបង្ហាញនូវការស្វាគមន៍ ស្រឡាញ់រាប់អានយ៉ាងកក់ក្ដៅចំពោះភ្ញៀវជាតិ និងអន្តរជាតិទាំងឡាយពីសំណាក់ថ្នាក់ដឹកនាំ និងសមាជិករដ្ឋសភាទាំងមូល ហើយក៏ជាសក្ខីភាពបញ្ជាក់នូវលក្ខណៈទន់ភ្លន់របស់ស្ត្រីខ្មែរយើងតាំងពីបុរាណកាលមក ។ នៅសងខាងជណ្ដើរឡើងទៅអគារធំក៏មាននាគមួយគូរបង្ហាញឫទ្ធីតេជៈ ដើម្បីស្វាគមន៍ធ្វើបដិសណ្ឋារកិច្ច និងការពារចំពោះភ្ញៀវទាំងឡាយផង ដែរ ។

នៅអគារផ្នែកខាងមុខ នៃច្រកចូលនេះមានលំនាំដូច អគារ "ព្រះចន្ទ័ឆាយា" ដែលនៅទីនេះមានសសរខ្ពស់ៗរាងបួនជ្រុង និងស្រឡះល្អ ។ នៅលើក្បាលសសរ និងជើងសសរមានក្បាច់រចនាតាមបែបរចនាប័ទ្មបន្ទាយស្រី កន្លែងនេះអាចរៀបចំជាពិធី

ផ្សេងៗ ដូចជារៀបចំដាក់បាត្រព្រះសង្ឃក្នុងពិធីបុណ្យទានជាប្រពៃណី ឬបុណ្យជាតិផ្សេងៗបានយ៉ាងសមរម្យ ។ នៅផ្នែកខាងលើនៃសសរនេះ គឺជាដំបូលដែលមានហោជាង ប្រដាប់ដោយក្បូរក្បាច់រចនាតាមរចនាប័ទ្មបន្ទាយស្រី ។ នៅខាងចុងនៃដំបូលមានលម្អដោយក្បាច់រងស្បូវ រូបគ្រុឌ នាគ ជហ្វា ...ពណ៌លឿងមាសយ៉ាងល្អឥតខ្ចោះរបស់សំណង់ខ្មែរក្នុងសម័យរុងរឿងដែលបង្កប់នូវអត្ថន័យផ្សេងៗទៀតក្នុងការការពារសំណង់ទាំងមូលនៃផ្នែកលំហ ។

## ២ . រូបភាពខាងក្នុង :

បន្ទាប់ពីបើកទ្វារធំចូល មានតាំងរូបសំណាកព្រះមហាវីរៈក្សត្រ **ព្រះបាទជ័យវរ្ម័នទី ៧** ឆ្លាក់ដោយថ្មភក់ភ្នំត្បែងមានកំពស់ ២,៨០ ម៉ែត្រ និងមានពាក្យស្លោករបសព្រះអង្គជាអក្សរចារិកថា "ទុក្ខវេទនារបស់ប្រជារាស្ត្រជាទុក្ខវេទនារបស់អាត្មាអញ"។

ចូលមកដល់ខាងក្នុងមានការតុបតែងលម្អនូវរូបចម្លាក់ ដោយថ្មភក់យកពីភ្នំគូលេនចំនួន ៣ ផ្ទាំងធំៗលើជញ្ជាំងទី ១ ដែលបង្ហាញអំពីព្រះរាជសកម្មភាពរបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រជាទីគោរពសក្ការៈបំផុតនៃយើង ពេលដែលព្រះអង្គទ្រង់ទាមទារឯករាជ្យជាតិ និងស្ថាបនាជាតិ ។ នៅផ្នែកខាងក្រោយនៃជញ្ជាំងមានតាំង " ព្រះពុទ្ធរូប " ដ៏ធំមួយជានិមិត្តរូបនៃជំនឿសាសនារបស់ប្រជារាស្ត្រខ្មែរ ដែលរដ្ឋធម្មនុញ្ញបានចែងថា " ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ " នៅខាងស្តាំព្រះពុទ្ធរូបមានចម្លាក់ស្តីពីការពិចារណារបស់ព្រះសុទ្ធតមុនពេលលោកចេញសាងព្រះផ្នួស នៅខាងឆ្វេងមានផ្ទាំងសីលាចារឹកមួយសរសេរអំពី បញ្ចសីលារបស់ព្រះពុទ្ធក្រោយពេលបានត្រាស់ជាព្រះពុទ្ធ និងទ្រង់ប្រោសសត្វ ។ នេះគឺជាទីលានមួយសម្រាប់ការសម្រាកក្រោយប្រជុំ ឬពិធីបុណ្យទានផ្សេងៗរបស់សមាជិករដ្ឋសភា ហៅថា " ទីលានតំណាងរាស្ត្រ " នៅជញ្ជាំងខាងកើតផ្នែកខាងលើមានរូបចម្លាក់ព្រះបាទ **សុរិយាវរ្ម័នទី ២** បង្ហាញអំពីសវនាការ

ដែលព្រះអង្គបានយកព្រះទ័យទុកដាក់ជាមួយប្រជារាស្ត្រនាសម័យអង្គរ ។ ចំណែកឯអគារស្លាបសងខាងគឺជាការិយាល័យរបស់ប្រធានរដ្ឋសភា និងអនុប្រធានទាំងពីរព្រមទាំងបន្ទប់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាដែលហាមមិនឱ្យសង់បន្ទប់អ្វីពីលើនេះទេ ។ នេះគឺជាការបញ្ជាក់ពីសិទ្ធិឯករាជ្យក្នុងការដឹកនាំ និងរៀបចំតាក់តែងច្បាប់ ។

នៅលើជញ្ជាំងខាងលិចនៃសាលពិព័រណ៍ ដែលស្ថិតនៅក្រោមសាលប្រជុំពេញអង្គមានឆ្លាក់អក្សរដែលរៀបរាប់ពីប្រវត្តិសង្ខេបនៃការកកើតច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកដំបូងនៅឆ្នាំ ១៩៤៧ រហូតដល់សព្វថ្ងៃ និងផ្នែកខាងក្រោមមានឆ្លាក់ភាគខ្លះៗនៃរឿង " កូរសមុទ្រទឹកដោះ " ជារឿងតំណាលអំពីអទិទេព " ទេវតា " និងយក្ស " អសុរិយ " ទាញព្រ័ត្រដើម្បីយកទឹកអម្រឹតផឹកការពារមិនឱ្យស្លាប់ ។ ការកូរសមុទ្រទឹកដោះនេះគេយក " ភ្នំមន្ទរៈ " ជាស្នូលនាគរាជឈ្មោះ " វសុកិ " ជាព្រ័ត្រសម្រាប់ទាញដោយពួកអសុរិយទាញខាងក្បាលទេវតាទាញខាងកន្ទុយ ។ ក្នុងពេលកូរសមុទ្រទឹកដោះ " ភ្នំមន្ទរៈ " នោះស្រុតចុះទៅក្រោមពេលនោះព្រះនារាយណ៍បានធ្វើបដិហារជាសត្វអណ្តើកដើម្បីទៅទ្រភ្នំកុំឱ្យមានការស្រុតចុះ ឬលម្អៀង ។ ការកូរសមុទ្រទឹកដោះនេះបានប្រារព្វអស់រយៈកាលដ៏យូរទើបកើតមានឡើងនូវដំរីឰរាវ័ណ សេះឧជ័យ ស្រវ្យ និងទេពអប្សរហោះហើរព្រោងព្រាត ។ ទឹកអម្រឹតនេះ បានមកពីពួកទេវតាដែលឈ្នះលើ ពួកអសុរិយ ។

ចំពោះទស្សនៈនយោបាយសង្គមបច្ចុប្បន្ន រឿងកូរសមុទ្រទឹកដោះ ជានិមិត្តរូបមួយដែលមានន័យសំខាន់ណាស់ទាក់ទងនឹងតួនាទីរបស់រដ្ឋសភាក្នុងការកសាងច្បាប់ និងសកម្មភាពនៃអង្គការនីតិប្រតិបត្តិដើម្បីការពារប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ប្រជារាស្ត្រទូទៅ ។ អសុរិយជាតំណាងនៃសភាវៈអាក្រក់ ដូចជាសង្គមដែលគ្មានច្បាប់ទម្លាប់អនាធិបតេយ្យ ចំណែកទេវតាតំណាងសមាជិកសភាដែលកើតចេញពីគ្រប់គណបក្សនានាហើយបានខិតខំប្រឹងប្រែងយ៉ាងពេញសមត្ថភាពក្នុងការអនុម័តច្បាប់សម្រាប់ការអនុវត្តន៍ក្នុងសង្គមប្រជាធិបតេយ្យដើម្បីជាផលប្រយោជន៍របស់ប្រទេស និងផលប្រយោជន៍

របស់ប្រជារាស្ត្រទូទៅ និងធ្វើឱ្យសង្គមមានសណ្តាប់ធ្នាប់ មានសន្តិសុខ មានស្ថេរភាព និងជំរុញឱ្យមានការអភិវឌ្ឍន៍សង្គមជាតិមានការរីកចំរើនជានិច្ចដូច " ទឹកអម្រឹត " ។

## ៣ . ប្រព័ន្ធរចនាប័ទ្មនៃសំណង់ :

ប្រព័ន្ធសំណង់អគារមានដូចខាងក្រោម :

**<u>អគារ A</u>**

**<u>ជាន់ផ្ទាល់ដី :</u>**

មានបន្ទប់តំកល់ឯកសារ ផ្ទុកសម្ភារៈ រោងពុម្ព បណ្ណាល័យ សាលពីរ (០២) សម្រាប់ទទួលភ្ញៀវមកពីខេត្តសាលតាំងពិព័រណ៌ សាលប្រជុំធំៗ ៣ ការិយាល័យរដ្ឋបាល និងការិយាល័យនៃគណៈកម្មការជំនាញរបស់រដ្ឋសភាចំនួនប្រាំពីរ ។

**<u>ជាន់ទី១ :</u>**

មានបន្ទប់ប្រធានរដ្ឋសភា អនុប្រធានទី ១ អនុប្រធានទី ២ និងខុទ្ទកាល័យបីបន្ទប់ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍មួយ បន្ទប់សម្រាប់នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី បន្ទប់គណៈកម្មការជំនាញនៃរដ្ឋសភា ចំនួន ២ អគ្គលេខាធិការ អគ្គលេខាធិការរង សន្តិសុខ ភេសជ្ជៈ និងមហាសាលប្រជុំពេញអង្គ។

**មហាសាលប្រជុំពេញអង្គ :** ជាន់ខាងលើ និងខាងក្រោមរៀបចំបានចំនួន ៤៤៥ កៅអីសម្រាប់សមាជិកនៃអង្គការនីតិប្បញ្ញត្តិ ។ ផ្នែកខាងក្នុងនៃមហាសាលប្រជុំពេញអង្គជាន់ខាងក្រោមមានរៀបចំកន្លែងគង់ប្រថាប់សម្រាប់ព្រះមហាក្សត្រ យាងមកបើកសម័យប្រជុំដំបូងនៃនីតិកាលនីមួយៗ ។ នៅចំកណ្តាលមានអាសនៈប្រធាន អនុប្រធានទី ១ និងអនុប្រធានទី ២ នៃរដ្ឋសភា អមដោយអាសនៈសម្រាប់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសមាជិករដ្ឋាភិបាល ។ ចំពីមុខ

ប្រធានរដ្ឋសភាមានប៉ូឌីយ៉ូម និងតុធ្វើកំណត់ហេតុ ឬ តុសម្រាប់បោះឆ្នោត និងតុកៅអីសមាជិក សមាជិការដ្ឋសភាទាំងអស់ និងខាងចុងបំផុតមានបន្ទប់ស្ទូឌីយូសម្រាប់បកប្រែភាសា និងបន្ទប់ត្រួតពិនិត្យ។

នៅសងខាងអាសនៈ មានកៅអីសម្រាប់ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងអង្គទូតនានា ។ ផ្នែកខាងលើមហាសាលប្រជុំពេញអង្គមានកន្លែងសម្រាប់ប្រជារាស្ត្រសមាគមសហគមន៍ អង្គការជាតិ និងអ្នកសារព័ត៌មានជាតិ អន្តរជាតិចូលរួមស្តាប់ ឬយកព័ត៌មាន។

**<u>អគារ B , D , D1 :</u>**

អគារនីមួយៗមានកំពស់ ៤ ជាន់ សម្រាប់ការិយាល័យ តំណាងរាស្ត្រ និងអ្នកជំនួយការ បន្ទប់ធ្វើការ និងបន្ទប់ទទួលភ្ញៀវរបស់តំណាងរាស្ត្រ ។ បន្ទប់ទាំងអស់មាន ១៥៩ បន្ទប់ ។

**<u>អគារ C :</u>**

មានកំពស់ ២ ជាន់

ជាន់ផ្ទាល់ដី : ជាអាហារដ្ឋាន

ជាន់ទី ១ : ជាកន្លែងហាត់ប្រាណ

ផ្ទៃលំហផ្នែកខាងក្រៅនៃអគារនីមួយៗលម្អទៅដោយស្ពាន មានដំបូលសម្រាប់ឆ្លងពីអគារមួយទៅអគារមួយទៀត ។ មានផ្លូវរថយន្តចូលចំពីមុខអគារ មានគូរទឹកព័ទ្ធជុំវិញអគារ និងសួនច្បារ ហើយមានភ្លើងគោមបំភ្លឺ តាមចំណតរថយន្ត ផ្លូវ សួនច្បារ របង និងក្លោងទ្វារ ។

## សេចក្តីសន្និដ្ឋាន :

យោងតាមការសិក្សាស្រាវជ្រាវអំពីទស្សនៈរចនាប័ទ្មរបស់ខ្មែរ យើងដូចដែលទូលព្រះបង្គំខ្ញុំបាទទូលថ្វាយ និងជម្រាបជូនខាងលើនេះហើយ ទើបគណៈកម្មការសាងសង់បានណែនាំឱ្យស្ថាបត្យករ រៀបចំគម្រោងប្លង់ទៅតាមតម្រូវការរបស់រដ្ឋសភា ហើយថែមទាំងបង្កប់នូវលក្ខណៈ សិល្បៈ វប្បធម៌ អរិយធម៌ និងភាពទំនើបរបស់ស្ថាបត្យកម្មខ្មែរ ធៀបទៅនឹងស្ថាបត្យកម្មបរទេស រួមបញ្ចូលក្នុងស្ថាបត្យកម្មទំនើបបែបលោកខាងលិច ។ សមិទ្ធផលនេះបង្ហាញនូវការយកចិត្តទុកដាក់ដ៏ខ្ពង់ខ្ពស់របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាព្រមទាំងថ្នាក់ដឹកនាំរដ្ឋសភាដទៃទៀតក្នុងការស្ថាបនាជាតិ និងរក្សាអត្តសញ្ញាណជាតិពិសេសរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ។

វិមានជាប្រវត្តិសាស្ត្រនៃរដ្ឋសភាដែលសម្ពោធនាពេលនេះ គឺជាទីកន្លែងធ្វើការដែលរដ្ឋផ្តល់ជូនតំណាងរាស្ត្រគ្រប់មណ្ឌលទូទាំងប្រទេសបំពេញការងារបំរើប្រជាពលរដ្ឋឱ្យបានពេញលេញតរៀងទៅ ។ វិមានដែលសាងសង់រួចនេះ គឺជាមោទនភាពនៃប្រជាជន និងមាតុភូមិកម្ពុជានៅលើឆាកអន្តរជាតិផងដែរ ។ មហាសមិទ្ធផលនេះជាចំណងដៃថ្មីមួយចំពោះអង្គការនីតិប្បញ្ញត្តិ ដែលជាខួបគម្រប់ទី ៦០ ឆ្នាំ នៃការបង្កើតរដ្ឋសភានៅព្រះរាជាណាចក្រកម្ពុជា (១៩៤៧–២០០៧)។

ខ្លឹមសារដូចទូលព្រះបង្គំខ្ញុំបាទបានទូលថ្វាយ និងជម្រាបជូនខាងលើនេះ សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាសូមទ្រង់ព្រះមេត្តាជ្រាប ព្រមទាំងគណៈអធិបតី និងអង្គពិធីទាំងមូលមេត្តាជ្រាបជារបាយការណ៍ដោយព្រះអនុគ្រោះ និងអនុគ្រោះ ។

នៅទីបញ្ចប់ ទូលព្រះបង្គំខ្ញុំបាទសូមបន់ស្រន់ដល់ទេវតា ឆ្នាំថ្មី ឆ្នាំកុរ នព្វស័ក ព.ស ២៥៥១ ព្រះនាម **មហោធរទេវី** សូមព្រះអង្គប្រមើល មើលដោយថ្វាយព្រះពរដល់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

សូមព្រះអង្គមានព្រះជន្មាយុយឺនយូរ រាប់រយព្រះវស្សា ទ្រង់មានព្រះសុខភាពល្អបរិបូណ៌ ព្រះកាយពលរឹងមាំ និងសូមព្រះអង្គទ្រង់គង់ក្នុងព្រះបរមសិរីរាជសម្បត្តិយូរអង្វែងតទៅ ដោយទ្រង់បានគង់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រខ្មែរតរៀងទៅ ។

សូមគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិសមប្រកប ដោយពុទ្ធពរទាំងប្រាំប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីប្រែក្លាយជាប្រការដទៃឡើយ ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាព្រះរាជទានទោសប្រោសប្រណី និងសូមអភ័យទោស ។

ក្រាបបង្គំទូលថ្វាយ និងជម្រាបជូននៅរាជធានីភ្នំពេញ
ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៧
ជ.ប្រធានគណៈកម្មការរៀបចំជួសជុល និងសាងសង់វិមានរដ្ឋសភាថ្មី
**ប្រធាន**

**បណ្ឌិត ជាម យៀប**